លេខ ៣៣ ចេញផ្សាយថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែកុម្ភៈ ឆ្នាំ២០២៤

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## ការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៤ ឆ្នាំ២០២៤

នាព្រឹកថ្ងៃព្រហស្បតិ៍ ៧ រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកឧត្តម **ឆន ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច អមដោយលោក **ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងសហការី បានអញ្ជើញចូលរួមកាត់កញ្ចប់វិញ្ញាសារប្រឡង និងប្រកាសបើកកម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៤ ឆ្នាំ២០២៤ នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច ជាន់ទី១៥។ ការប្រឡងនេះ បានបញ្ចប់ទៅដោយរលូន និងជោគជ័យ។




រូបភាព៖ ការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៤ ឆ្នាំ២០២៤។

## មាតិកា


- ការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៤ ឆ្នាំ២០២៤ ទំព័រទី១
- ទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍នៅធនាគារជាតិនៃប្រទេសថៃ និងសមាគមបច្ចេកវិទ្យាហិរញ្ញវត្ថុថៃ ទំព័រទី២
- វគ្គបណ្តុះបណ្តាលស្តីពី របៀបរៀបចំ និងសរសេររបាយការណ៍ហិរញ្ញវត្ថុ ទំព័រទី២
- ប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) ទំព័រទី៣
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែមករា ឆ្នាំ២០២៤ និងទិសដៅការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៤ ទំព័រទី៣
- កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២៣ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ទំព័រទី៣
- ពិធីបិទកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២៣ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ទំព័រទី៤
- សិក្ខាសាលាស្តីពី ការបូកសរុបលទ្ធផលការងារអនុវត្តគម្រោងឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤ នៃគម្រោង ACSEP សមាសភាគទី១ ទំព័រទី៤
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី ការដាក់ឱ្យអនុវត្តគេហទំព័ររបស់ **ន.ប.ធ.** ជាផ្លូវការ ទំព័រទី៥
- កម្មវិធីបើកបវេសនកាល ២០២៣-២០២៤ និងប្រគល់បណ្ណសរសើរ និងមេដាយជូននិស្សិតឆ្នើមរបស់វិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ ទំព័រទី៥
- កម្មវិធីជជែកអំពីបរធនបាលកិច្ច ក្រោមប្រធានបទស្តីពី បរធនបាលកិច្ច÷យន្តការសម្រាប់ការវិនិយោគអចលនទ្រព្យប្រកបដោយទំនុកចិត្ត ទំព័រទី
- វេទិកាសាធារណៈស្តីពីការផ្សព្វផ្សាយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០២៤ ទំព័រទី៦
- កិច្ចប្រជុំពិភាក្សាលើ សេចក្តីព្រាងច្បាប់ភូមិបាល ទំព័រទី៧
- កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) ទំព័រទី៧
- កិច្ចប្រជុំជាមួយប្រតិភូធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពី ការពិនិត្យវឌ្ឍនភាពការងារក្នុងឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤ ទំព័រទី៨
- សិក្ខាសាលាស្តីពី ការល្បែងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ទំព័រទី៨
- កិច្ចប្រជុំពិភាក្សាការងាររវាង **ន.ប.ធ.** ជាមួយក្រុមហ៊ុន VTeam Financial Services Group ទំព័រទី៩
- កិច្ចប្រជុំពិភាក្សាលើវឌ្ឍនភាពនៃការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនបាលកិច្ចសម្រាប់រយៈពេល ១០ ឆ្នាំ (២០២៣-២០៣២) ទំព័រទី៩
- សិក្ខាសាលាស្តីពី ការល្បែងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ទំព័រទី៩
- កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តថវិកាប្រចាំឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទំព័រទី១០
- កិច្ចប្រជុំពិភាក្សាការងាររវាង **ន.ប.ធ.** ជាមួយក្រុមវិនិយោគិនមកពីក្រុមហ៊ុន United Credit Services នៅប្រទេសចិន ទំព័រទី១០
- កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយហិរញ្ញប្បទានជាតិ ទំព័រទី១១




អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## ទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍នៅធនាគារជាតិ នៃប្រទេសថៃ និងសមាគមបច្ចេកវិទ្យាហិរញ្ញវត្ថុថៃ

ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (**អ.ស.ហ.**), ចាប់ពីថ្ងៃទី ១-២ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តមអគ្គនាយករង និងសហការីនៃ **ន.ប.ធ.** បានធ្វើទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍នៅធនាគារជាតិនៃប្រទេសថៃ និងសមាគមបច្ចេកវិទ្យាហិរញ្ញវត្ថុថៃ ពាក់ព័ន្ធនឹងយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ, បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech's Regulatory Sandbox), បច្ចេកវិទ្យាគ្រប់គ្រងទ្រព្យ-សម្បត្តិ (WealthTech), បច្ចេកវិទ្យាប្លុកឆេន (Blockchain Technology), គម្រោងបច្ចេកវិទ្យាអនាគត, បទល្មើសបច្ចេកវិទ្យា (Digital and Cyber Fraud), ក្របខណ្ឌគតិយុត្ត និងការគ្រប់គ្រងត្រួតពិនិត្យហានិភ័យ។




រូបភាព៖ ទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍នៅធនាគារជាតិនៃប្រទេសថៃ និងសមាគមបច្ចេកវិទ្យាហិរញ្ញវត្ថុថៃ។

## វគ្គបណ្តុះបណ្តាលស្តីពី របៀបរៀបចំ និងសរសេររបាយការណ៍ហិរញ្ញវត្ថុ

កាលពីព្រឹកថ្ងៃចន្ទ ១១រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួត-ប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្មសម្រាប់សមាសភាគទី១ (ACSEP PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**ក.ស.ហ.វ.**) បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "របៀបរៀបចំ និងសរសេររបាយការណ៍ហិរញ្ញវត្ថុ" សម្រាប់ស្ថាប័នហិរញ្ញវត្ថុដៃគូនៃគម្រោង ACSEP ក្រោមអធិបតីភាពរបស់ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោង ACSEP PIU1 នៅទីស្តីការរបស់ **ន.ប.ធ.** ជាន់ទី៨។ កម្មវិធីនេះ មានការចូលរួមដោយថ្នាក់ដឹកនាំ និងមន្ត្រីនៃផ្នែកទាំង៤ នៃគម្រោង ACSEP-PIU1, ទីប្រឹក្សារបស់ ACSEP PIU1 និងក្រុមការងារមកពីធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា និងមានការធ្វើបទបង្ហាញដោយលោក **សួន សុភា** អ្នកជំនាញការទទួលបន្ទុកផ្នែកគ្រប់គ្រងហានិភ័យឥណទាន នៃគម្រោង ACSEP-PIU។




រូបភាព៖ វគ្គបណ្តុះបណ្តាលស្តីពី របៀបរៀបចំ និងសរសេររបាយការណ៍ហិរញ្ញវត្ថុ។

## ប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃអង្គារ ១២រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៦ ខែមករា ឆ្នាំ២០២៤ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍ស្ថាប័ននៃនិយ័តករបរធនបាលកិច្ចសម្រាប់រយៈពេល ១០ឆ្នាំ (២០២១-២០៣០) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **រស់ សីលវ៉ា** អនុប្រធាន **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។




រូបភាព៖ ប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែមករា ឆ្នាំ២០២៤ និងទិសដៅការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៤

នាព្រឹកថ្ងៃព្រហស្បតិ៍ ១៤រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកឧត្តម **នេន ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែមករា ឆ្នាំ២០២៤ និងទិសដៅការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៤ ក្នុងកម្រិតអន្តរនាយកដ្ឋាន រួមមាន នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងនាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច។ កិច្ចប្រជុំនេះ មានការចូលរួមពីលោក/លោកស្រីប្រធាននាយកដ្ឋាន លោកអនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យ និងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានទាំងពីរ។

នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តមអគ្គនាយករងបានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែមករា ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានទាំងពីរ និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



រូបភាព៖ កិច្ចប្រជុំបូកសរុបការងារប្រចាំខែមករា ឆ្នាំ២០២៤ និងទិសដៅការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៤។

## កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២៣ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤

ថ្ងៃអង្គារ ៤កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តម **ណឹ សារាល** អគ្គនាយករងនៃ **ន.ប.ធ.**, លោក **យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២៣ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅសណ្ឋាគារហ្គាឌិនស៊ីធី។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២៣ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤។

## ពិធីបិទកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២៣ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤

នាព្រឹកថ្ងៃពុធ ៥កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តម **ឈឺ សាគល** អគ្គនាយករងនៃ **ន.ប.ធ.**, លោក **យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមពិធីបិទកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២៣ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងមានការចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃរាជរដ្ឋាភិបាល, ឯកឧត្តម **ឌៀសម៉ាន់ អ៊ីហ្គោរ៍** (Diesmans Igor) ឯកអគ្គរដ្ឋទូតប្រតិភូសហភាពអឺរ៉ុប និងជាតំណាងដៃគូអភិវឌ្ឍន៍, ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួង-ស្ថាប័ន, ដៃគូអភិវឌ្ឍន៍, ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត, និងតំណាងអង្គការមិនមែនរដ្ឋាភិបាល នៅសណ្ឋាគារសុខា ភ្នំពេញ។






រូបភាព៖ ពិធីបិទកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២៣ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤។

## សិក្ខាសាលាស្តីពី ការបូកសរុបលទ្ធផលការងារអនុវត្តគម្រោងឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤ នៃគម្រោង ACSEP សមាសភាគទី១

នាព្រឹកថ្ងៃសុក្រ ៧កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់-តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្មសម្រាប់សមាសភាគទី១ (ACSEP PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (**ក.ស.ហ.វ.**) បានរៀបចំសិក្ខាសាលាស្តីពី "ការបូកសរុបលទ្ធផលការងារអនុវត្តគម្រោងឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤" នៃគម្រោង ACSEP សមាសភាគទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ACSEP PIU1 នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច ជាន់ទី១៥។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណង ដើម្បីពិភាក្សាលើបញ្ហាប្រឈម កាលានុវត្តភាព និងដំណោះស្រាយ ដែលបានអនុវត្តកន្លងមក និងសំណូមពរនានារបស់អង្គភាពពាក់ព័ន្ធ ជាពិសេសស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ ក្នុងដំណើរការអនុវត្តគម្រោង ពាក់ព័ន្ធនឹងដំណើរការប្រតិបត្តិការផ្នែកឥណទានក្នុងឆ្នាំ២០២៣ ដើម្បីឈានទៅរកដំណោះស្រាយសមស្របរួមគ្នាមួយសម្រាប់ ការរៀបចំយុទ្ធសាស្ត្រអនុវត្ត ឱ្យបានល្អប្រសើរជាងនេះ សម្រាប់ ឆ្នាំ២០២៤។

សិក្ខាសាលានេះ មានការចូលរួមពីសមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, តំណាងមកពីអគ្គនាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលនៃ **ក.ស.ហ.វ.**, តំណាងអង្គភាពគ្រប់គ្រងគម្រោងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីររួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



រូបភាព៖ សិក្ខាសាលាស្តីពី ការបូកសរុបលទ្ធផលការងារអនុវត្តគម្រោងឆ្នាំ ២០២៣ និងទិសដៅការងារឆ្នាំ២០២៤ នៃគម្រោង ACSEP សមាសភាគទី១។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី ការដាក់ឱ្យអនុវត្តគេហទំព័ររបស់ ន.ប.ធ. ជាផ្លូវការ

នារសៀលថ្ងៃសុក្រ ៧កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤, និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការដាក់ឱ្យអនុវត្តគេហទំព័ររបស់ **ន.ប.ធ.** ជាផ្លូវការ" ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ ឯកឧត្តមអគ្គនាយករង ប្រធាននាយកដ្ឋាន និងសហការីទាំងអស់នៃ **ន.ប.ធ.** ដោយមានការចូលរួមដោយផ្ទាល់ពីតំណាងមកពីនិយ័តករ និងអង្គភាពក្រោមឱវាទនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងតំណាងមកពីបរធនបាល, ប្រតិបត្តិករផ្តល់សេវារក្សាទុក ឬសេវារក្សាសុវត្ថិភាពក្នុងវិស័យបរធនបាលកិច្ច, ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច និងបុគ្គលពាក់ព័ន្ធផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច នៅមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច (BDC)។ គោលបំណងនៃសិក្ខាសាលានេះ គឺដើម្បីប្រកាសដាក់ឱ្យអនុវត្តនូវគេហទំព័រ (Website) របស់ **ន.ប.ធ.** ជាផ្លូវការ ក៏ដូចជាដើម្បីធ្វើការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយបន្ថែមទៀតនូវ Website របស់ **ន.ប.ធ.** ទៅដល់និយ័តករនិងអង្គភាពក្រោមឱវាទ **អ.ស.ហ.**, តួអង្គនិងភាគីពាក់ព័ន្ធទាំងអស់នៅក្នុងវិស័យបរធនបាលកិច្ច និងសាធារណជន ដែលសំដៅដល់ការដាក់ឱ្យអនុវត្តប្រកបដោយសណ្តាប់ធ្នាប់ តម្លាភាព និងទំនុកចិត្ត ក៏ដូចជាការផ្តល់នូវភាពងាយស្រួលដល់អ្នកចូលមើល (Visitor) ក្នុងការទាញយកនូវរាល់ឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច ជាដើម។



រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយស្តីពី ការដាក់ឱ្យអនុវត្តគេហទំព័ររបស់ ន.ប.ធ. ជាផ្លូវការ។

## កម្មវិធីបើកបវេសនកាល ២០២៣-២០២៤ និងប្រគល់បណ្ណសរសើរ និងមេដាយជូននិស្សិតឆ្នើមរបស់វិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ

នារសៀលថ្ងៃអាទិត្យ ៩កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមជាអធិបតីភាព ក្នុងកម្មវិធីបើកបវេសនកាល ២០២៣-២០២៤ និងប្រគល់បណ្ណសរសើរ និងមេដាយជូននិស្សិតឆ្នើមរបស់វិទ្យាស្ថានហិរញ្ញវត្ថុ និង គណនេយ្យ។

នៅក្នុងកម្មវិធីនេះ ឯកឧត្តមអគ្គនាយក បានផ្តល់កិត្តិយសចូលរួមធ្វើបាឋកថាស្តីពី "វិស័យបរធនបាលកិច្ចនៅកម្ពុជា" និងប្រគល់បណ្ណសរសើរ និងមេដាយដល់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ២៥ រូប។ កម្មវិធីនេះ មានការអញ្ជើញចូលរួមដោយ ឯកឧត្តម **ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា លោកនាយក គណៈគ្រប់គ្រង លោក-លោកស្រីសាស្ត្រាចារ្យ និងនិស្សិតនៃវិទ្យាស្ថានហិរញ្ញវត្ថុនិងគណនេយ្យ។



*រូបភាព៖* កម្មវិធីបើកបវេសនកាល ២០២៣-២០២៤ និងប្រគល់ប័ណ្ណសរសើរ និងមេដាយជូននិស្សិតឆ្នើមរបស់វិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ។

## កម្មវិធីជជែកអំពីបរធនបាលកិច្ច ក្រោមប្រធានបទស្តីពី បរធនបាលកិច្ច៖ យន្តការសម្រាប់ការវិនិយោគ អចលនទ្រព្យប្រកបដោយទំនុកចិត្ត

នាព្រឹកថ្ងៃចន្ទ ១០កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ដោយអនុវត្តតាមស្មារតីនៃអនុស្សរណៈនៃការយោគយល់គ្នារវាង និយ័តករបរធន-បាលកិច្ច (**ន.ប.ធ.**) និងសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា (CVEA) ស្តីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹង និងជំរុញការចូលរួមក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" **ន.ប.ធ.** និងសមាគម CVEA បានសហការរៀបចំកម្មវិធីជជែកអំពីបរធនបាលកិច្ច ក្រោមប្រធានបទស្តីពី "បរធនបាលកិច្ច៖ យន្តការសម្រាប់ការវិនិយោគអចលនទ្រព្យប្រកបដោយទំនុកចិត្ត" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង លោក **សន សៀប** ប្រធានសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។

កម្មវិធីនេះត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីបញ្ជ្រាបការយល់ដឹងឱ្យបានកាន់តែស៊ីជម្រៅពាក់ព័ន្ធនឹងវិសាលភាព និងគុណប្រយោជន៍នៃយន្តការបរធនបាលកិច្ចដល់ថ្នាក់ដឹកនាំ និងសមាជិក-សមាជិកានៃសមាគម CVEA ដែលជាតួអង្គពាក់ព័ន្ធដ៏សំខាន់ក្នុងទីផ្សារបរធនបាលកិច្ចនៅកម្ពុជា និងដើម្បីទាញយកផលប្រយោជន៍ជាអតិបរមាពីយន្តការបរធនបាលកិច្ចសម្រាប់ធុរកិច្ចរបស់ខ្លួន។

កម្មវិធីនេះក៏មានការចូលរួមផ្តល់បទបង្ហាញដោយ លោក **រិន រដ្ឋា** អនុប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច លោកស្រី **យស ស៊ីរតនា** ប្រធានផ្នែកច្បាប់ និងអនុលោមភាព នៃក្រុមហ៊ុន កាណា ត្រាស, លោក **ព្រឿង សុភាព** នាយកគ្រប់គ្រងទូទៅនៃក្រុមហ៊ុន ហ្វីលីព ត្រាសធី (ខេមបូឌា) និងលោក **ស៊ីយ៉ា ម៉ាលីដា** នាយកការិយាល័យប្រតិបត្តិការមូលបត្រ នៃធនាគារ អេស៊ីលីដា ភីអិលស៊ី ផងដែរ។



*រូបភាព៖* កម្មវិធីជជែកអំពីបរធនបាលកិច្ច ក្រោមប្រធានបទស្តីពី "បរធន-បាលកិច្ច៖ យន្តការសម្រាប់ការវិនិយោគអចលនទ្រព្យប្រកបដោយទំនុកចិត្ត"។

## វេទិកាសាធារណៈស្តីពីការផ្សព្វផ្សាយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់គ្រប់គ្រងឆ្នាំ២០២៤

នាព្រឹកថ្ងៃចន្ទ ១០កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកឧត្តម **ណើ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយលោក **ឃុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ និងសហការី បានអញ្ជើញចូលរួមវេទិកាសាធារណៈស្តីពីការផ្សព្វផ្សាយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០២៤ ក្រោមការដឹកនាំជា

សហប្រធានរបស់ ឯកឧត្តមបណ្ឌិត **ផាន់ ផល្លា** និង ឯកឧត្តម **ចាន់ សុធី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន តំណាងដៃគូអភិវឌ្ឍន៍ តំណាងអង្គការមិនមែនរដ្ឋាភិបាល និងអង្គភាពពាក់ព័ន្ធ នៅសណ្ឋាគារហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ។



**រូបភាព៖** វេទិកាសាធារណៈស្ដីពីការផ្សព្វផ្សាយច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០២៤។

## កិច្ចប្រជុំពិភាក្សាលើ សេចក្ដីព្រាងច្បាប់ភូមិបាល

នារសៀលថ្ងៃពុធ ១២កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកឧត្តម **នខ ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ លោកស្រី **ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាលើ "សេចក្ដីព្រាងច្បាប់ភូមិបាល" ក្រោមអធិបតីភាព ឯកឧត្តម **ស៊ាន ផល្លា** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅទីស្ដីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីតំណាងអគ្គនាយកដ្ឋានពន្ធដារ, តំណាងនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ និងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផងដែរ។



**រូបភាព៖** កិច្ចប្រជុំពិភាក្សាលើ "សេចក្ដីព្រាងច្បាប់ភូមិបាល"។

## កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃពុធ ១២កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ លោក **ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្ដុះបណ្ដាល និងសហប្រតិបត្តិការ និង លោក **ណង សេរីវុធ** អនុប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្ដុះ-បណ្ដាល និងសហប្រតិបត្តិការ អមដោយសហការី បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារសេចក្ដីព្រាងនៃអនុក្រឹត្យស្ដីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្ដិរបស់មន្ត្រីអធិការកិច្ចធានារ៉ាប់រងរបស់និយ័តករធានារ៉ាប់រងកម្ពុជា និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ឆ្នាំ២០២៣-២០៣២ របស់និយ័តករគណនេយ្យនិងសវនកម្ម ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **រស់ សីលវ៉ា** អនុប្រធាន **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។




**រូបភាព៖** កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។

## កិច្ចប្រជុំជាមួយប្រតិភូធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពី ការពិនិត្យវឌ្ឍនភាពការងារក្នុងឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤

នាព្រឹកថ្ងៃព្រហស្បតិ៍ ១៣កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោង ACSEP PIU1 អមដោយសហការី បានដឹកនាំកិច្ចប្រជុំជាមួយប្រតិភូធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពី "ការពិនិត្យវឌ្ឍនភាពការងារក្នុងឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤" នៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ជាន់ទី១២។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីពិនិត្យលើវឌ្ឍនភាពការងារក្នុងឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤ និងដើម្បីពិភាក្សាលើបញ្ហាប្រឈម និងដំណោះស្រាយក្នុងដំណើរការអនុវត្តគម្រោងពាក់ព័ន្ធនឹងដំណើរការប្រតិបត្តិការផ្នែកឥណទានក្នុងឆ្នាំ២០២៣ ព្រមទាំងដើម្បីរៀបចំយុទ្ធសាស្រ្តអនុវត្តឱ្យបានកាន់តែល្អប្រសើរសម្រាប់ឆ្នាំ២០២៤។

កិច្ចប្រជុំនេះ មានការចូលរួមដោយ លោកស្រី **Hyunyoung Song** ប្រធានក្រុមបេសកកម្ម ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងប្រតិភូអមដំណើរ, លោក **Wong Keet Loong** នាយកប្រតិបត្តិសាជីវកម្មធានាឥណទានកម្ពុជា និងសហការី, សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, តំណាងមកពីអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលនៃ **ក.ស.ហ.វ.**, តំណាងអង្គភាពគ្រប់គ្រងគម្រោងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីររួមមានធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



**រូបភាព៖** កិច្ចប្រជុំជាមួយប្រតិភូធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពី ការពិនិត្យវឌ្ឍនភាពការងារក្នុងឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤។

## សិក្ខាសាលាស្តីពី ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា

នាព្រឹកថ្ងៃសុក្រ ១៤ កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងវិទ្យាស្ថានជាតិពាណិជ្ជសាស្រ្តបានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង លោក **ទា អ៊ីវហួត** នាយករងនៃវិទ្យាស្ថានជាតិពាណិជ្ជសាស្រ្ត នៅវិទ្យាស្ថានជាតិពាណិជ្ជសាស្រ្ត។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅវិទ្យាស្ថាន អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ចបទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។

កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ, និងនិស្សិត នៃវិទ្យាស្ថានជាតិពាណិជ្ជសាស្រ្ត។



**រូបភាព៖** សិក្ខាសាលាស្តីពី ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំពិភាក្សាការងាររវាង ន.ប.ធ. ជាមួយក្រុមហ៊ុន VTeam Financial Services Group

នាព្រឹកថ្ងៃសុក្រ ១៤កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញទទួលជួបប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន VTeam Financial Services Group តំណាងដោយលោក ស្រី **Nicole Chen** នាយករងក្រុមហ៊ុន VTeam Financial Services Group ជាក្រុមហ៊ុនមានជំនាញខ្ពស់លើបច្ចេកវិទ្យាហិរញ្ញវត្ថុនៅប្រទេសចិន ដើម្បីពិភាក្សាអំពីកាលានុវត្តភាពសម្រាប់ការវិនិយោគនៅកម្ពុជា និងស្វែងយល់អំពីការអភិវឌ្ឍទីផ្សារបរធនបាលកិច្ច ក៏ដូចជាគំនិតផ្តួចផ្តើមនានា ដើម្បីអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ និងទីផ្សារបរធន-បាលកិច្ចនៅកម្ពុជា នាពេលខាងមុខផងដែរ។



រូបភាព៖ កិច្ចប្រជុំពិភាក្សាការងាររវាង **ន.ប.ធ.** ជាមួយក្រុមហ៊ុន VTeam Financial Services Group។

## កិច្ចប្រជុំពិភាក្សាលើវឌ្ឍនភាពនៃការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនបាលកិច្ចសម្រាប់រយៈពេល ១០ ឆ្នាំ (២០២៣-២០៣២)

នារសៀលថ្ងៃសុក្រ ១៤កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំក្រុមការងាររៀបចំយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនបាលកិច្ចសម្រាប់រយៈពេល ១០ ឆ្នាំ (២០២៣-២០៣២) ដើម្បីប្រជុំពិនិត្យ និងពិភាក្សាលើវឌ្ឍនភាពនៃការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនបាលកិច្ចសម្រាប់រយៈពេល ១០ ឆ្នាំ (២០២៣-២០៣២) តាមប្រព័ន្ធអនឡាញ (Zoom)។ កិច្ចប្រជុំពិភាក្សានេះ មានការអញ្ជើញចូលរួមដោយ ឯកឧត្តមអគ្គនាយករង លោក/លោកស្រីប្រធាននាយកដ្ឋាន និងសមាជិកក្រុមការងាររៀបចំយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនបាលកិច្ចសម្រាប់រយៈពេល ១០ ឆ្នាំ (២០២៣-២០៣២)។




រូបភាព៖ កិច្ចប្រជុំពិភាក្សាលើវឌ្ឍនភាពនៃការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនបាលកិច្ចសម្រាប់រយៈពេល ១០ ឆ្នាំ (២០២៣-២០៣២)។

## សិក្ខាសាលាស្តីពី ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា

នាព្រឹកថ្ងៃចន្ទ ២រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ និយ័តករបរធន-បាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យជាតិជាស៊ីម កំចាយមារ សាខាខេត្តកំពង់ចាម បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងលោក **ជិន ពិសិដ្ឋ** នាយកប្រតិបត្តិសាខាសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ ខេត្តកំពង់ចាម នៅសាកលវិទ្យាល័យជាតិជាស៊ីម កំចាយមារ សាខាខេត្តកំពង់ចាម។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងគុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមដោយថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ, និងនិស្សិត នៃសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ សាខាខេត្តកំពង់ចាម។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ សិក្ខាសាលាស្តីពី ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។

## កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តថវិកាប្រចាំឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នាព្រឹកថ្ងៃអង្គារ ៣រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយលោក **យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំត្រួតពិនិត្យការអនុវត្តថវិកាប្រចាំឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងក្របខណ្ឌ **កសហវ** នៅទីស្តីការ កសហវ។



រូបភាព៖ កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តថវិកាប្រចាំឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## កិច្ចប្រជុំពិភាក្សាការងាររវាង ន.ប.ធ. ជាមួយក្រុមវិនិយោគិនមកពីក្រុមហ៊ុន United Credit Services នៅប្រទេសចិន

នារសៀលថ្ងៃពុធ ៤រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញទទួលជួបប្រជុំពិភាក្សា ការងារជាមួយក្រុម-វិនិយោគិនមកពីក្រុមហ៊ុន United Credit Services នៅប្រទេសចិន ដែលដឹកនាំដោយលោក Jim Brown នាយកប្រតិបត្តិ នៃក្រុមហ៊ុន United Credit Services ដើម្បីពិភាក្សាអំពីកាលានុវត្តភាពសម្រាប់ការវិនិយោគនៅកម្ពុជា និងស្វែងយល់អំពីការអភិវឌ្ឍទីផ្សារបរធនបាលកិច្ច ក៏ដូចជាគំនិតផ្តួចផ្តើមនានា ដើម្បីអភិវឌ្ឍទីផ្សារបរធនបាលកិច្ចនៅកម្ពុជា នាពេលខាងមុខផងដែរ។



រូបភាព៖ កិច្ចប្រជុំពិភាក្សាការងាររវាង **ន.ប.ធ.** ជាមួយក្រុមវិនិយោគិនមកពីក្រុមហ៊ុន United Credit Services នៅប្រទេសចិន។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្ដីព្រាងក្របខ័ណ្ឌគោលនយោបាយហិរញ្ញប្បទានជាតិ

នាថ្ងៃព្រហស្បតិ៍ ៥ រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកឧត្តម **ណឹ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយលោក **ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្ដុះបណ្ដាល និងសហប្រតិបត្តិការ និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្ដីព្រាងក្របខ័ណ្ឌគោលនយោបាយហិរញ្ញប្បទានជាតិ ក្រោមអធិបតីភាពរបស់ឯកឧត្តម **ម៉ែន ធីរុទ្ធ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលោកស្រី Alissar Chaker តំណាង UNDP ប្រចាំប្រទេសកម្ពុជា នៅសណ្ឋាគារហ្វៃរហ្វៀល បាយ ម៉ារៀត ភ្នំពេញ។

កិច្ចប្រជុំនេះមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ធនាគារជាតិនៃកម្ពុជា អង្គការជាតិ-អន្តរជាតិ ស្ថាប័នឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀត។




**រូបភាព៖** កិច្ចប្រជុំពិភាក្សាការងាររវាង **ន.ប.ធ.** ជាមួយក្រុមវិនិយោគិនមកពីក្រុមហ៊ុន United Credit Services នៅប្រទេសចិន។